ថ្នាំលាបការពារជម្រាបទឹកសម្រាប់ផ្ទៃបេតុង និងជញ្ជាំងឥដ្ឋ

# Sikalastic®-215 DRYLOK®

## ការណែនាំអំពីការប្រើប្រាស់

**ជំហានទី 1**



### រៀបចំផ្ទៃ

ចាប់ផ្តើមដោយសម្អាតធូលី ខ្លាញ់ ប្រេង និងសារធាតុកខ្វក់ផ្សេងៗ ពីផ្ទៃដើម្បីឱ្យការលាប ផលិតផលជ្រាបចូលបានស្អិតល្អលើផ្ទៃ។

**ជំហានទី 2**



### ជួសជុលផ្ទៃឱ្យរាបស្មើ

ជួសជុលស្នាមប្រេះ រន្ធ និងចំណុចខូចខាតទាំងអស់ រួមទាំងបិទចំណុចប្រសព្វរវាងជញ្ជាំង និងកម្រាល ដើម្បីទទួលបានផ្ទៃរាបស្មើសម្រាប់ការលាប។

**ជំហានទី 3**



### ករណីផ្ទៃសើម

សម្រាប់ផ្ទៃដែលមានសំណើម ឬបញ្ហាជ្រាបទឹក សូមទាក់ទងមកក្រុមការងារស៊ីកា ដើម្បីទទួលបានការណែនាំអំពីការប្រើប្រាស់ឲ្យបានត្រឹមត្រូវ។

**ជំហានទី 4**



### ការលាយផលិតផល

កូរ SIKALASTIC®-215 DRYLOK ដោយប្រើម៉ាស៊ីនក្នុងល្បឿនយឺតៗរហូតល្បាយសព្វល្អ ។

**ជំហានទី 5**



### ករណីផ្ទៃស្ងួត

លាប SIKALASTIC®-215 DRYLOK® ជាទ្រនាប់ PRIMER ដោយប្រើជក់ក្នុងអត្រា 0.2–0.3 គក/ម$^{2}$ ហើយទុកឱ្យស្ងួតប្រហែល 45នាទី។ (ត្រូវប្រាកដថាកម្រិតសំណើមរបស់ផ្ទៃមិនលើសពី 5%)

**ជំហានទី 6**



### ការលាបស្រទាប់ទី1 (Base Coat)

បន្ទាប់ពីស្រទាប់ Primer ស្ងួត លាបស្រទាប់ទី1 ដោយប្រើជក់ រ៉ូឡូ ឬម៉ាស៊ីនបាញ់ស្រេយ៍ ដើម្បីបង្កើតស្រទាប់ការពារជម្រាបទឹកដ៏រឹងមាំ។

**ជំហានទី 7**



### ការលាបស្រទាប់ទី2 (Finish Coat)

លាបស្រទាប់ទី2 ឬស្រទាប់ចុងក្រោយ ដោយប្រើជក់ រ៉ូឡូ ឬម៉ាស៊ីនបាញ់ស្រេយ៍ ដើម្បីបំពេញប្រព័ន្ធការពារជម្រាបទឹក និងបង្កើនភាពរឹងមាំក្នុងការប្រើប្រាស់ឱ្យបានរយៈពេលយូរអង្វែង។

**ជំហានទី 8**



### តំហែទាំ

បន្ទាប់ពីទុកឱ្យស្ងួតល្អរយៈពេល 24 ម៉ោង ផ្ទៃអាចលាបថ្នាំពណ៌ពីលើបាន។


**SIKA (CAMBODIA) LTD.**
Phaum Prek Kampeus,
Sangkat Prek Kampeus,
Khan Dangkor, 120510,
Phnom Penh, Cambodia.



© SIKACAMBODIA/WATERPROOFING/07.2026



All orders are accepted subject to our current terms of sale and delivery. Users should always refer to the most recent issue of the Product Data Sheet for the product concerned.


BUILDING TRUST




# Sikalastic®-215 DRYLOK®

## ថ្នាំលាបការពារជម្រាបទឹកសម្រាប់ផ្ទៃបេតុង និងជញ្ជាំងឥដ្ឋ


BUILDING TRUST

Sikalastic®-215 DRYLOK®

# Sikalastic®-215 DRYLOK®

## ថ្នាំលាបការពារជម្រាបទឹកសម្រាប់ផ្ទៃបេតុង និងជញ្ជាំងឥដ្ឋ

Sikalastic®-215 DRYLOK® ជាផលិតផលការពារជម្រាបទឹកសម្រាប់បេតុង និងជញ្ជាំងសំណង់ ដែលប្រើប្រាស់បច្ចេកវិទ្យាប៉ូលីម័រពិសេស អាចជ្រៀតចូលទៅក្នុងផ្ទៃដែលមានរន្ធតូចៗ និងមានសមត្ថភាពចូលទៅភ្ជិតរន្ធតូចៗបានយ៉ាងមានប្រសិទ្ធភាព (Capillary Pores) ដែលបង្កើតជាស្រទាប់ការពារដ៏រឹងមាំ ធ្វើឲ្យផ្ទៃរលោងស្អាត និងប្រើប្រាស់បានយូរអង្វែង។ ផលិតផលនេះមានសារធាតុ Biocide ដែលជួយទប់ស្កាត់ការកកើតផ្សិត និងស្លែ។ វាត្រូវបានធ្វើតេស្តស្របតាមស្តង់ដារ ASTM D7088 ដែលអាចទប់នឹងសម្ពាធទឹកបានរហូតដល់ 15 PSI (~1.03 bar) ដែលស្មើនឹងសម្ពាធទឹកពីជញ្ជាំងទឹកកម្ពស់ 10 ម៉ែត្រ។



## ការប្រើប្រាស់

- សម្រាប់បេតុង ឥដ្ឋ និងស៊ីម៉ង់ត៍បូកទាំងខាងក្នុង និងខាងក្រៅ
- ការពារជម្រាបទឹកសម្រាប់បន្ទប់ក្រោមដី រណ្ដៅជណ្តើរយន្ត អាងស្តុកទឹក ផ្ទះបាយ បន្ទប់ទឹក ជញ្ជាំង និងតំបន់ផ្សេងៗដែលត្រូវការការពារទឹកជ្រាប
- អាចលាបថ្នាំពណ៌ពីលើបាន




## បច្ចេកទេសផលិតផល

Sika®Monotop 102 ជួសជុលស្នាមប្រេះធំៗ និងទប់ស្កាត់ការលេចធ្លាយទឹកបានយ៉ាងមានប្រសិទ្ធភាព

Sikadur®-20 Crack seal បំពេញស្នាមប្រេះតូចៗបានយ៉ាងមានប្រសិទ្ធភាព

## គុណសម្បត្តិ

- ទប់ស្កាត់ការជ្រាបទឹកបាន ទោះស្ថិតក្រោមសម្ពាធទឹកក៏ដោយ
- ទប់នឹងសម្ពាធទឹកបានរហូតដល់ 15 PSI (~1.03 bar) ដែលស្មើនឹងសម្ពាធទឹកពីជញ្ជាំងទឹកកម្ពស់ 10 ម៉ែត្រ
- ជួយទប់ស្កាត់ការកកើតផ្សិត និងស្លែ
- ពណ៌សភ្លឺ និងផ្ទៃរលោងស្អាត
- ជួយកាត់បន្ថយបញ្ហាផ្ការអំបិលដុះលើផ្ទៃ (Efflorescence)
- ងាយស្រួលប្រើប្រាស់







SINGAPORE GREEN BUILDING PRODUCT S G B C EXCELLENT
SGBP 6303

ពណ៌៖ ស

អាយុកាលផលិតផល៖ 2ឆ្នាំ

ការវេចខ្ចប់៖ ចំណុះ 5 គីឡូ/ធុង